00660512

E74

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 04 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

## អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២** កាលបរិច្ឆេទ: ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១**

បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានធ្វើការបញ្ជាក់ដោយផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ អង្គជំនុំជម្រះសូមបញ្ជាក់ប្រាប់ភាគីឲ្យបានជ្រាបថា ខ្លឹមសារខាងក្រោមនេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះ ទៅនឹងសំណើសុំដែលកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង៖

សំណើរបស់ អៀង សារី សុំសេចក្តីណែនាំដែលកំណត់ថាវេលាកំណត់នឹងមិនត្រូវរាប់រហូតដល់ពេលមានការជូនដំណឹងអំពីការដាក់ឯកសារជាភាសាផ្លូវការទាំងពីររបស់មេធាវីការពារក្តី (ឯកសារលេខ E67)៖

> ជាករណីលើកលែង វិសោធនកម្មទៅលើសេចក្តីណែនាំអនុវត្តន៍នាពេលថ្មីៗនេះទាក់ទងនឹងការដាក់ឯកសារដែលបានធ្វើនៅចំពោះមុខអង្គជំនុំជម្រះ បានអនុញ្ញាតឲ្យភាគីដាក់ឯកសារតែមួយភាសាបាន នៅពេលមានបញ្ហាប្រឈមផ្នែកបកប្រែភាសាដោយមិនអាចឲ្យភាគីដាក់ឯកសារជាភាសាខ្មែរ និងភាសាអង់គ្លេស ឬភាសាបារាំងបានក្នុងពេលតែមួយ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាការចាប់ផ្តើមរាប់ពេលវេលាក្នុងការដាក់ឯកសារនឹងរាប់នៅពេលណាដែលមានការជូនដំណឹងពីការដាក់ភាសាខ្មែរទៅក្នុងសំណុំរឿង។ ការអនុវត្តនានាទាក់ទងនឹងបញ្ហាទាំងនេះ និងបញ្ហាផ្សេងទៀតនឹងមានការវិវឌ្ឍន៍នៅពេលដំណើរការជំនុំជម្រះប្រព្រឹត្តទៅ (ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ៨)។

ពាក់ព័ន្ធនឹងសំណើរបស់ អៀង សារី ស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថ ប្រសិនបើត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្មអំពីអ្វីដែលពួកគាត់បានដឹងពីរឿងក្តីព្រហ្មទណ្ឌ (ឯកសារលេខ E57)៖

00660513

E74

> អង្គជំនុំជម្រះកត់សម្គាល់ផងដែរនូវសំណើរបស់មេធាវីការពារក្តីលោក អៀង សារី អំពីការធ្វើសម្បថ នៅពេលដើមបណ្តឹងរដ្ឋប្បវេណីធ្វើសក្ខីកម្មនៅពេលជំនុំជម្រះ (ឯកសារលេខ E57)។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជ្រើសរើសដើម្បីធ្វើជាសាក្សី ហើយដែលត្រូវធ្វើសម្បថនោះ បញ្ហានីតិវិធីមិនចោទជាបញ្ហាឡើយ។ វិធាន ២៣(៤), ២៤ និង ៣១ នៃវិធានផ្ទៃក្នុងបានគូសបញ្ជាក់រួចហើយអំពីបុគ្គលណាខ្លះដែលត្រូវធ្វើសម្បថតាមបទដ្ឋានរបស់ អ.វ.ត.ក នោះ (ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ៨៣ (ដោយមានការកែប្រែបន្តិចបន្តួចនៅពេលបន្ទាប់))។

ជាការឆ្លើយតបទៅនឹងសំណើរបស់ អៀង សារី ស្នើសុំឱ្យ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ធ្វើសម្បថដើម្បីផ្តល់សក្ខីកម្ម ប្រសិនបើត្រូវបានកោះហៅធ្វើជាសាក្សី (ឯកសារលេខ E56) អង្គជំនុំជម្រះសូមបញ្ជាក់ថាអង្គជំនុំជម្រះនឹងកោះហៅ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ជាសាក្សីធម្មតាក្នុងសំណុំរឿង ០០២ ប្រសិនបើខ្លួនសម្រេចធ្វើដូច្នេះ។ អនុលោមតាមវិធាន ២៤(១) គាត់នឹងត្រូវធ្វើសម្បថ។ អង្គជំនុំជម្រះយល់ឃើញថាវិធាន ២៤(៤) ពុំហាមឃាត់ពិរុទ្ធជន ក្នុងសំណុំរឿង ០០១ មិនឱ្យផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីក្នុងសំណុំរឿង ០០២ ឡើយ។ ប្រសិនបើដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ពុំទាន់បញ្ចប់នៅពេលពិរុទ្ធជនត្រូវធ្វើសក្ខីកម្ម អង្គជំនុំជម្រះនឹងនៅតែស្តាប់សក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ក្នុងនាមជាសាក្សីដែលបានស្បថរួច ក្រោយពីមានការណែនាំត្រឹមត្រូវពីសំណាក់អង្គជំនុំជម្រះពាក់ព័ន្ធនឹងសិទ្ធិមិនឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង។

ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ក៏បានដាក់សំណើសុំមួយចំនួនជំទាស់ទៅនឹងផ្នែកខ្លះនៃកិច្ចស៊ើបសួរ (*សូមមើល ឧទាហរណ៍ដូចជា* សំណើរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី និងសំណើសុំបើកសវនាការស្តីពីការបំពេញកិច្ចស៊ើបសួរ (E71))។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់គោលការណ៍ណែនាំខាងក្រោមជូនដល់ភាគីនៅក្នុងបញ្ហានេះ៖

> អង្គជំនុំជម្រះបានទទួលនូវសំណើសុំជាច្រើន ទាក់ទងនឹងការជំទាស់ទៅលើការមិនអាចទទួលយកបាននូវផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ហានៅដំណាក់កាលស៊ើបអង្កេត។ អង្គជំនុំជម្រះនឹងមិនលើកបង្ហាញនូវសារណាតបនានាដែលខ្លួនបានទទួលនោះទេ។ សំណើសុំដែលបានដាក់ទាំងនោះមានខ្លឹមសារសង្ខេបជារួមដូចខាងក្រោម៖
>
> ក. មានការភាន់ច្រឡំក្នុងកិច្ចស៊ើបអង្កេត ដែលនាំឱ្យកិច្ចស៊ើបអង្កេតមួយចំនួនត្រូវចាត់ទុកថាមោឃៈ។
>
> ខ. មានការភាន់ច្រឡំជាច្រើននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឧទាហរណ៍ ដីកានេះមិនបានបង្ហាញទឡ្ហីករណ៍ឱ្យបានច្បាស់លាស់។ ជាបច្ច័យ ផ្នែកជាច្រើននៃដីកាត្រូវតែលុបចេញ។

00660514

E74

គ. ដោយសារតែបទចោទមួយចំនួននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់នោះ នាំឱ្យមានបញ្ហានៃការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌។

វាមានភាពច្បាស់លាស់ដែលថាអង្គជំនុំជម្រះត្រូវជំនុំជម្រះទៅតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះយោងទៅលើវិធាន៦៧(២), ៧៦(៧) និងវិធាន ៨៩(១)(គ)។ នៅពេលអានវិធាននេះបញ្ចូលគ្នានោះគឺមិនអាចមានមូលដ្ឋានឱ្យអង្គជំនុំជម្រះធ្វើការកែប្រែទៅលើដីកាដែលខ្លួនបានទទួលទេ ហើយក៏មិនអាចពិចារណាអំពីថាតើនីតិវិធីនៅដំណាក់កាលនៃការស៊ើបអង្កេតមានកំហុសនោះដែរ។ ប្រសិនបើមានភាពមិនច្បាស់លាស់នៅដំណាក់កាលនៃការជំនុំជម្រះ អង្គជំនុំជម្រះនឹងពិចារណាតាមករណីនីមួយៗដោយធ្វើការបកស្រាយអត្ថន័យនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយការបកស្រាយនេះនឹងចងកាតព្វកិច្ចអង្គជំនុំជម្រះ (ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ៨១)។

សំណើរបស់ អៀង សារី ស្នើសុំការណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារលេខ E23)៖

នៅក្នុងសំណើមួយចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ មេធាវីការពារក្តី អៀង សារី បានដាក់សំណើមួយចំពោះមុខអង្គជំនុំជម្រះ (ឯកសារលេខ E23) ស្នើសុំឱ្យពិភាក្សា និងកំណត់ពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។អង្គជំនុំជម្រះកត់សម្គាល់ពីការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីចាប់តាំងពីសំណុំរឿងលេខ ០០១ មក។ ដោយយោងទៅលើវិធាន ២៣(៣) ដែលត្រូវបានធ្វើវិសោធនកម្មនៅក្នុងកិច្ចប្រជុំពេញអង្គលើកទីប្រាំថែងថា "ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅដើមបណ្តឹងរដ្ឋប្បវេណីត្រូវរួមបញ្ចូលក្រុមតែមួយ ដែលផលប្រយោជន៍របស់ពួកគាត់ត្រូវបានតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី"។ វិធាននេះកំណត់ធ្វើការបែងចែកខុសគ្នាអំពីការចូលរួមនៅមុនដំណាក់កាលជំនុំជម្រះដែលដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមជាលក្ខណៈបុគ្គលបាន។ វិធាននេះបានបង្កើតឱ្យមានប្រព័ន្ធនៃការចូលរួមរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីតែមួយ ដែលនឹងត្រូវតំណាងដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ ជាជាងការតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីជាលក្ខណៈបុគ្គលដែលត្រូវបានតំណាងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចសម្រេចចាត់តាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ ដើម្បីចូលរួមក្នុងសវនាការទៅលើចំណុចជាក់លាក់ណាមួយ។ ទោះបីជាយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងដែលត្រូវបានធ្វើវិសោធនកម្មកន្លងមកនេះ មិនបានអនុញ្ញាតឱ្យមេធាវីនីមួយៗ ដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិជាស្វ័យប្រវត្តិចំពោះមុខអង្គជំនុំជម្រះឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា បញ្ហាជាច្រើនទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺត្រូវបានចែងរួចហើយនៅក្នុងវិធានផ្ទៃក្នុង ពិសេសវិធាន ២១(១)(ក) និង ២១(៤) វិធាន ៨៥, វិធាន ៨៧ (៣) និង៨៧(៤) និងវិធាន ៩១(៣)។ អង្គជំនុំជម្រះយល់ថា វិធានទាំងនេះគឺមានលក្ខណៈគ្រប់គ្រាន់ ក្នុងការកំណត់ពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី។ ដូច្នេះ អង្គជំនុំជម្រះនឹងមិនចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើសំណើនេះទៀតទេ។ អង្គជំនុំជម្រះធ្វើការយោងទៅលើ

សេចក្តីសម្រេចរបស់ខ្លួនដែលបានប្រកាសដោយផ្ទាល់មាត់ កាលពីថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩ និងជាលាយលក្ខណ៍អក្សរគឺ "សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំឱ្យសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សី ដែលបានកោះហៅឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ" (ឯកសារលេខ E72/3 សំណុំរឿងលេខ ០០១)។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើចំណុចនេះគឺនៅរក្សាដដែល។ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើអន្តរាគមន៍ទាក់ទងនឹងបញ្ហាផ្តន្ទាទោសបានទេ (ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៨២-៨៣)។

សំណើរបស់ អៀង សារី សុំជំទាស់ទៅនឹងការប្រើប្រាស់សម្ភារៈទាំងឡាយ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមែប្រមូល (ឯកសារលេខ E59) (និងពាក់ព័ន្ធជាទូទៅនឹងការជំទាស់ទៅនឹងសំណួរដែលបានសួរក្នុងសវនាការ)៖

ភាគីខ្លះបានស្នើសុំការបញ្ជាក់បំភ្លឺអំពីទម្លាប់អនុវត្តរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការជំទាស់។ អង្គជំនុំជម្រះសូមរម្លឹកអំពីវិធាន ៨៧ ឡើងវិញ ដែលឆ្លុះបញ្ចាំងអំពីទម្លាប់អនុវត្តទូទៅក្នុងប្រព័ន្ធស៊ីវិល "civil law"។ អង្គជំនុំជម្រះសូមរម្លឹកឱ្យភាគីបានដឹងថាអនុលោមតាមវិធាន ៨៧ និងវិធាន ៨៥ អង្គជំនុំជម្រះអាចបដិសេធសំណើសុំពិនិត្យភស្តុតាង ប្រសិនបើខ្លួនយល់ថាសំណើនេះពុំចាំបាច់ និងពុំនាំទៅដល់ការបញ្ជាក់ការពិត ឬច្រំដែល, ពុំអាចរកបានក្នុងពេលសមស្រប, មិនសមស្របនឹងបញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង, ច្បាប់ពុំអនុញ្ញាត, មានចេតនាពន្យារកិច្ចនីតិវិធី ឬគ្មានប្រយោជន៍។ លក្ខខណ្ឌទាំងអស់នេះក៏អាចយកមកអនុវត្តចំពោះការធ្វើសក្ខីកម្មផ្ទាល់មាត់ដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងចាត់ការទៅលើការជំទាស់នានាម្តងមួយករណី ប្រសិនបើការជំទាស់ទាំងនោះមានសំអាងហេតុត្រឹមត្រូវ (ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ៧៨)។

សំណើរបស់ អៀង សារី ស្នើសុំជំទាស់ទៅនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មក្នុងពេលជំនុំជម្រះ (ឯកសារលេខ E33) ៖

អង្គជំនុំជម្រះបានទទួលសំណើមួយ ដែលជំទាស់ទៅនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មនៅក្នុងពេលជំនុំជម្រះ ដែលបានដាក់ដោយក្រុមមេធាវីការពារក្តី អៀង សារី (ឯកសារលេខ E33)។ ក្រុមមេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះប្រកាសកុំទទួលយកភស្តុតាងណា ដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មទោះក្នុងរូបភាព និងកាលៈទេសៈណាក្តី លើកលែងតែភស្តុតាងនោះជាភស្តុតាងចោទមកលើជនជាប់ចោទពីបទប្រព្រឹត្តទារុណកម្ម ដើម្បីបញ្ជាក់អំណះអំណាងដែលបានលើកឡើង។ មេធាវីការពារក្តីបានស្នើទៀតថាភាគីណាមួយដែលមានបំណងផ្តល់ភស្តុតាង ដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ជាដំបូងត្រូវ

បង្ហាញថាខ្លួនយកភស្តុតាងប្រភេទនេះមកប្រើប្រាស់ គឺដើម្បីគោលបំណងខាងលើតែប៉ុណ្ណោះ។ សំណើខាងលើពុំមានសំណូមពរណាមួយជាក់លាក់ឡើយ ពាក់ព័ន្ធនឹងបញ្ជីឯកសារភស្តុតាងណាមួយដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២។ ដូច្នេះ អង្គជំនុំជម្រះសូមឲ្យភាគីចាប់អារម្មណ៍ទៅលើសេចក្តីសម្រេចក្នុងសំណុំរឿង ០០១ ពិសេសក្នុងសវនាការថ្ងៃទី ២០ និងថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ពាក់ព័ន្ធនឹងការយកចម្លើយសារភាពធ្វើជាភស្តុតាង។ (ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ៨០)។

សំណើរបស់ អៀង សារី ស្នើសុំដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ (ឯកសារលេខ E20)៖

បើទោះបីជាអង្គជំនុំជម្រះបានទទួលសំណើសុំជាច្រើនពីភាគីស្នើឲ្យអង្គជំនុំជម្រះសម្រេចជាមុនអំពីចំនួនថ្ងៃ និងចំនួនម៉ោងជំនុំជម្រះប្រចាំថ្ងៃនៃសវនាការក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថាវាជាការលឿនពេកនៅក្នុងដំណាក់កាលនេះដើម្បីកំណត់អំពីរយៈពេលសម្រាប់សវនាការប្រចាំថ្ងៃនោះ។ ផ្ទុយទៅវិញ សេចក្តីសម្រេចទាំងនេះនឹងត្រូវធ្វើឡើងបន្ទាប់ពីមានការធ្វើសេចក្តីសន្និដ្ឋានពីអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ។ អង្គជំនុំជម្រះនឹងផ្តល់ព័ត៌មានបន្ថែមដល់ភាគីទាំងអស់នៅក្នុងពេលសមស្របខាងមុខ (ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ៤២-៤៣)។

អង្គជំនុំជម្រះក៏បានឃើញផងដែរនូវសំណើរបស់មេធាវីការពារក្តីរបស់ អៀង សារី ស្នើសុំការបញ្ជាក់ថាតើសេចក្តីសម្រេច និងដីកាបង្គាប់នានាដែលមានហត្ថលេខារបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ធ្វើឡើងតាងនាមឲ្យអង្គជំនុំជម្រះសាលាដំបូងទាំងមូល ឬយ៉ាងណា (ឯកសារលេខ E73)។ ទោះបីយើងឃើញមានភាពខុសគ្នាតិចតួចនៅក្នុងទម្រង់នៃសេចក្តីសម្រេចទាំងឡាយរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងក្តី ក៏តាមរយៈការអានសេចក្តីសម្រេចទាំងនេះ ធ្វើឲ្យយើងដឹងច្បាស់ថាសេចក្តីសម្រេចទាំងនេះត្រូវបានចេញដោយតាងនាមឲ្យអង្គជំនុំជម្រះទាំងមូល។ លើសពីនេះទៀត នេះគឺជាទម្លាប់អនុវត្តទូទៅរបស់តុលាការកម្ពុជា និងតុលាការអន្តរជាតិឯទៀត។

អង្គជំនុំជម្រះសូមបញ្ជាក់ទៀតថា អនុស្សរណៈទាំងឡាយរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងក៏ត្រូវបានចេញតាមការណែនាំរបស់អង្គជំនុំជម្រះ និងជាគោលការណ៍ណែនាំសម្រាប់ភាគី។ ប្រសិនបើភាគីពុំអើពើទៅនឹងគោលការណ៍ណែនាំនេះ ភាគីនឹងអាចរងទណ្ឌកម្មវិន័យពីសំណាក់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះសូមរម្លឹកដល់ក្រុមមេធាវីការពារក្តីរបស់ អៀង សារី អំពីសេចក្តីណែនាំចំពោះភាគីនៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលមានដូចខាងក្រោម៖

00660517

E74

ដើម្បីកាត់បន្ថយការបកប្រែឯកសារ និងបញ្ហាប្រឈមផ្សេងទៀត និងដើម្បីធានាការរៀបចំសវនាការឲ្យមានប្រសិទ្ធភាព ប្រសិនបើអាចធ្វើបាន ភាគីនានាត្រូវបានជម្រុញឲ្យលើកឡើងអំពីការព្រួយបារម្ភ ឬស្នើសុំព័ត៌មានជាលក្ខណៈក្រៅផ្លូវការពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបាន។ ក្នុងកម្រិតដែលអាចធ្វើទៅបាន និងសមស្រប វិធីនេះគួរតែយកមកប្រើប្រាស់ជំនួសឲ្យការដាក់សំណើសុំដែលគ្រាន់តែធ្វើការស្វែងរកព័ត៌មាន ឬលើកជាសំណួរនោះ។ កន្លងមក អង្គជំនុំជម្រះធ្លាប់បានផ្ដល់អនុសាសន៍មិនឲ្យផ្ដល់ប្រាក់កម្រៃចំពោះការដាក់ឯកសារមួយចំនួនដែលអង្គជំនុំជម្រះយល់ឃើញថាមិនមានមូលដ្ឋានផ្លូវច្បាប់ និងគ្រាន់តែជាការបន្ថែមបន្ទុកមកលើអង្គជំនុំជម្រះ និងសេវាបកប្រែប៉ុណ្ណោះ។ អង្គជំនុំជម្រះសូមរំឭកដល់មេធាវីអំពីកាតព្វកិច្ចរបស់ខ្លួនផ្អែកតាមវិធាន ២២ អនុវិធាន(៤) នៃវិធានផ្ទៃក្នុង... (ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០១១, ទំព័រ ១០)។